## អេម៉ានូអែល

សំលេងពីព្រះសហគមន៍កាតូលិក

**FM: 91 Mhz ខេត្តបាត់ដំបង**

*៧:៣០ នាទី រៀងរាល់ល្ងាចថ្ងៃសៅរ៍*

**FM: 88 Mhz ខេត្តកំពង់ធំ**

*១២:៣០- ១:៣០ នាទី រៀងរាល់ល្ងាចថ្ងៃសៅរ៍*

**FM: 102.5 Mhz ខេត្តសៀមរាប**

*១០:០០-១១:០០ នាទី រៀងរាល់ថ្ងៃសៅរ៍*

## ការិយាល័យផ្សព្វផ្សាយព័ត៌មាន ព្រះសហគមន៍ កាតូលិក រតនៈ

- បំលែងឯកសារពី VHS ទៅ DVD ទៅ VCD
- បំលែងចំរៀងពី កាសែតចម្រៀង ទៅ CD
- បង្កើតឯកសារវីឌីអូ សំរាប់ លោកឪពុក បងស្រី បងប្រុស។

ទំនាក់ទំនង ០៩២ ៦០៩ ៨៤៨

## ព័ត៌មានប្រចាំខែ ភូមិភាគ បាត់ដំបង

- ថ្ងៃទី ១៤ កក្កដា: បិទវគ្គសាលាមត្តេយ្យ និងផ្តល់រង្វាន់ ប័ណ្ណសសើរ ក្នុងឱកាសរ៉ាកងធំ ដែលមានរយៈពេល ៣ខែ នៅព្រះសហគមន៍ ចំណោម។
- ថ្ងៃទី ២០ កក្កដា: មាននិស្សិត មកពីប្រទេស សាំហ្គាពួរ បានមកលេងមណ្ឌលសិស្ស ទេពអ៊ីម ក្នុងព្រះសហគមន៍ កាតូលិកបាត់ដំបង។ ក្រុមនិស្សិត សាំហ្គាពួរ ទាំងអស់មានចំនួន ២៥នាក់ ស្រីចំនួន ១៥ នាក់ និងប្រុស១០នាក់។ ពួរគេស្នាក់នៅក្នុងមណ្ឌល ទេពអ៊ីម ចំនួន ២ថ្ងៃ។

## ល្បែងកំសាន្ត

សូមសង្កេត មើលមាន ចំនុច ៨ ដែលខុសគ្នា





Apostolic Prefecture of Battambang Monthly News. For Internal Circulation

# រតនៈ RATTANAK

មហាគ្រួសារព្រះសហគមន៍ កាតូលិក

Our Family

ព័ត៌មានព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង ប្រចាំខែ កក្កដា ឆ្នាំ ២០១២ លេខ ៤១



## ពិធីបុណ្យរំលឹកខួបសន្ត អ៊ីញ៉ាស្យូ ទទួលមរណៈភាព

## មាតិកា


- កម្មវិធីបិទវគ្គ សិស្សទទួលអាហាររូបករណ៍ពីព្រះសហគមន៍ ទំព័រ ២
- សិស្សថ្នាក់ស្វែងយល់ចំនួន៣២នាក់ ទទួលជំហានទី១ ទំព័រ ៦
- កម្មវិធីបិទវគ្គការប្រកួតបាល់ទាត់ជ្រើសរើសជើងឯក Bishop Cup ប្រចាំឆ្នាំ២០១២ ទំព័រ ៤-៥

ទំព័រ ៣

# កម្មវិធីបិទវគ្គ សិស្សទទួលអាហាររូបករណ៍

Photo: Moy samet




ដោយៈ មុយ សាម៉េត

កម្មវិធីបទវគ្គសិស្សទទួលអាហាររូបករណ៍ បានប្រព្រឹត្តទៅកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១២ នៅព្រះសហគមន៍កាតូលិកបាត់ដំបង។ កម្មវិធីនេះធ្វើឡើងក្នុងគោលបំណងពីរគឺ ទីមួយចង់បង្ហាញពីការគោរព នឹងអរគុណដល់ព្រះសហគមន៍កាតូលិកបាត់ដំបង ដែលបានផ្តល់អាហាររូបករណ៍ ដល់ពួកគេក្នុងការសិក្សារៀនសូត្របន្ថែម និងបំពេញនូវរាល់ការលំបាករបស់ពួកគេ។ ចំនែកទីពីរ គឺចង់បង្ហាញពីសិស្សគំរូល្អ ដែលទទួលបានលទ្ធផលល្អក្នុងការសិក្សារបស់ពួកគេ ដែលទទួលបានចំណាក់ថ្នាក់លេខ១ប្រចាំខែ។ ក្នុងនោះក៏មានការចូលរួមពីលោកឪពុក តូតេត និងគណៈកម្មការណ៍ របស់ព្រះសហគមន៍កាតូលិកបាត់ដំបង ព្រមទាំងមានសិស្សានុសិស្សប្រមាណ៣៥នាក់ផងដែរ។ បន្ទាប់ពីតំណាងសិស្សម្នាក់ បានអាននូវរបាយការណ៍រួចមក អ្នកស្រី ហែម បូរី ជាគណៈកម្មការណ៍របស់ព្រះសហគមន៍ កាតូលិកបាត់ដំបង បានមានប្រសាសន៍ និងមានចំណាត់អារម្មណ៍ដែលថា "តាមរបាយការណ៍ ដែលបានស្តាប់របាយការណ៍សិស្ស ខ្ញុំយល់ថាមានពីរចំនុច ហើយសម្រាប់ចំនុចទីមួយនោះ គឺចំនុចល្អ តែចំនុចទីពីរនោះជាចំនុចពុំសូវល្អ ប៉ុន្តែសម្រាប់អ្នកដែរល្អ សុំបន្តការព្យាយាមទៅមុខទៀត ចំនែកសិស្សពុំសូវល្អ សុំខិតខំប្រឹងប្រែងក្នុងការរៀនសូត្រ ពីព្រោះការរៀនមិនមានថ្ងៃចប់នោះទេ ហើយវាក៏ជាចំណេះ ដើម្បីសម្រេចគោលដៅនៃអនាគត។ យើងត្រូវមានការតស៊ូដោយមានការជួយឧបត្ថម ពីព្រះសហគមន៍ ដូចនេះ គេជួយនៅពេលដែរយើងខំ បើសិនជាយើងមិនខំទេ ការជួយរបស់យើងប្រាកដជាអសារបង់ ហើយធ្វើអោយខាតលុយ ខាតពេលវេលាខ្លួនឯងក្នុងការរៀនសូត្រផងដែរ"។ អ្នកស្រីបានបន្តទៀតថា "ដើម្បីឲ្យជីវិតបានប្រសើរ យើងត្រូវការរៀនដូចមានពាក្យស្លោកថា ចេះមកពីរៀន មានមកពីរក បើមិនយកចិត្តទុកដាក់រៀនទេនោះ ក៏យើងមិនចេះដែរ ប៉ុន្តែបើយើងខំរៀន ព្រះជាម្ចាស់នឹងប្រទានពរឲ្យនូវអំណោយទានមកដល់យើង"។ ស្របពេលនោះដែរលោកបូជាចារ្យ តូតេត បានមានប្រសាសន៍ថា "ខ្ញុំសប្បាយចិត្តណាស់ នូវពេលបានស្តាប់នូវរបាយការណ៍របស់កូនៗយ៉ាងក្បោះក្បាយ និងកម្មវិធីជាច្រើនសម្រាប់ឆ្នាំនេះ។ ក្នុងពេលនេះខ្ញុំ អរគុណដល់កូនៗទាំងអស់ ដែលបានខិតខំរៀនសូត្រ ទោះបីព្រះសហគមន៍ មិនបានផ្តល់ច្រើនយ៉ាងណាក្តី មានតែសម្រាប់ការរៀនគួរ។ កូនៗខ្លះមានទីលំនៅឆ្ងាយធ្វើអោយមានផល់លំបាកចំពោះកូនៗ ប៉ុន្តែកូនៗមានការតស៊ូរ ដើម្បីមកដល់ព្រះវិហារជារៀងរាល់ថ្ងៃអាទិត្យ និងបានជួយដល់ព្រះសហកមន៍វិញ។ ក្នុងនោះដែលសិស្សពូកែម្នាក់ឈ្មោះ វង្ស យីវ បាននិយាយក្នុងកម្មវិធីបិតវគ្គនេះថា "ដោយសារការជួយឧបត្ថម្ភ របស់លោកឪពុក ធ្វើអោយកូនបានរៀនរហូតមកដល់ពេលនេះ ហើយព្រមទាំងបានលើកទឹកចិត្ត ដល់ពួកកូនក្នុងការរៀនសូតបានល្អប្រសើរ។ ចុងបញ្ចប់នៃកម្មវិធីបិទវគ្គ ក៏មានការចែករង្វាន់ដល់សិស្សពូកែ ដែលរៀនមានចំណាត់ថ្នាក់លេខ១ប្រចាំថ្នាក់រៀងរាល់ខែ។



# សន្តី ថេរេសា នៅក្រុង លីស៊ីយឺ

**ក្នុងរតនះលេខមុន យើងបានស្គាល់ សន្តី ថេរេសា នៅក្រុង លីស៊ីយឺ រីឯលេខនេះគឺ យើងបន្តអាននូវប្រវត្តិ របស់សន្តី ថេរេសា បន្តទៀត។ តើ ថេរេសា បានមើលលិខិតទីប៉ុន្មានរបស់គ្រីស្តទូតប៉ូល? តើ ថេរេសា មានចិត្តយ៉ាងដូចម្តេចចំពោះចំម្លើយរបស់គ្រីស្តទូតប៉ូល? ដូចនេះ សូមអានក្នុងអត្ថបទខាងក្រោម នេះទាំងអស់គ្នា។**



ប៉ុណ្ណឹងល្មមគួរឲ្យនាងខ្ញុំពេញចិត្ត ហើយ (...)ប៉ុន្តែមិនអញ្ចឹងទេ(...)។ នៅក្នុងដួងចិត្តរបស់នាងខ្ញុំ មានការត្រាស់ហៅផ្សេងៗទៀត។ នាងខ្ញុំជ្រាបថា នាងខ្ញុំមានការត្រាស់ហៅជាអ្នកប្រយុទ្ធ សំរាប់ព្រះជាម្ចាស់បូជាចារ្យជាគ្រីស្តទូត ជាបណ្ឌិតជនមរណៈសាក្សី ព្រមទាំងមានចិត្តចង់បំពេញគ្រប់កិច្ចការដ៏អស្ចារ្យថ្វាយទៅព្រះយេស៊ូ។ ឱព្រះយេស៊ូអើយ! ព្រះអង្គជាសេចក្តីស្រលាញ់របស់នាងខ្ញុំ ជាជីវិតរបស់នាងខ្ញុំ (...)ធ្វើដូចម្តេចដើម្បីបង្រួម ការត្រាស់ហៅដែលខុសប្លែកពីគ្នាទាំងនោះ ធ្វើដូចម្តេចដើម្បីបំពេញចំនងចិត្តទាំងប៉ុន្មាននៃព្រលឹងដ៏តូចរបស់នាង ខ្ញុំ?"(...)។ "នៅពេលរិះគិតពីបំណងចិត្តរបស់ខ្ញុំនាងខ្ញុំកើតទុក្ខវេទនា។ ពេលនោះនាងខ្ញុំបានបើកព្រះគម្ពីរ ហើយមើលលិខិតសាសនទូតប៉ូល ដើម្បីរកចំលើយដែលធ្វើឲ្យនាងខ្ញុំធូរចិត្តខ្លះ។ គឺនាងខ្ញុំបានមើលលិខិតទី១ របស់គ្រីស្តទូតប៉ូលផ្ញើរជូនគ្រីស្តបរិស័ទ ក្រុងកូរិនថូស ត្រង់ជំពូកទី១២និង១៣។ ក្នុងជំពូកទី១២ នាងខ្ញុំបានយល់ថា គ្រីស្តបរិស័ទមិនអាចទៅជាគ្រីស្តទូតផង,ទៅជាព្យាការីផង, ទៅជាបណ្ឌិតផង...!ដ្បិតចំលើយរបស់លោកប៉ូលច្បាស់ហើយ ប៉ុន្តែមិនបំពេញចំណងចិត្តរបស់នាងខ្ញុំទេ និងមិនធ្វើឲ្យនាងខ្ញុំបានធូរចិត្តទេ។ ពេលនោះនាងខ្ញុំមិនទាន់ធ្លាក់ទឹកចិត្តទេ នាងខ្ញុំបានអានបន្តទៅមុខទៀតរហូតទៅដល់ឃ្លាមួយ ដែលធ្វើឲ្យនាងខ្ញុំបានធូរចិត្តៈ "ចូរប៉ងប្រាថ្នាចង់បានព្រះអង្គក៏ប៉ុន្តែខ្ញុំចង់បង្ហាញប្រាប់បងប្អូន អំពីមាគ៌ាមួយទៀត ដែលប្រសើរលើសលុបបំផុត" (១ករ១២,៣១)។ តពីនេះគ្រីស្តទូតប៉ូលពន្យល់ថា ប្រសិនជាខ្ញុំគ្មានសេចក្តីស្រលាញ់ទេ គ្រប់ព្រះអំណោយទានគ្មានប្រយោជន៍អ្វីទេ! គឺសេចក្តីជាផ្លូវដ៏ប្រសើរជាងគេ នាំយើងឆ្ពោះទៅព្រះជាម្ចាស់។ ពេលនោះទើប នាងខ្ញុំបានសេចក្តីសុខសាន្ត(...)។ សេចក្តីស្រលាញ់បានធ្វើឲ្យនាងខ្ញុំយល់ពីការត្រាស់ហៅរបស់នាងខ្ញុំ។ នាងខ្ញុំបានយល់ថា៖........(តលេខក្រោយ)

# សិស្សថ្នាក់ស្វែងយល់ចំនួន៣២នាក់ ទទួលជំហានទី១

ដោយៈ អាន ឫទ្ធីរដ្ឋ

**ជំនឿរបស់គ្រីស្តបរិស័ទ ពឹងផ្អែកទៅលើព្រះគ្រីស្ត ទៅលើព្រះបន្ទូល ទៅលើព្រះសហគមន៍ ជាទីពំនឹងពំនាក់ ក្នុងការរស់នៅប្រចាំថ្ងៃ ដោយធ្វើតាមគំរូរបស់ព្រះយេស៊ូ។ ដូច្នេះហើយទើបព្រះសហគមន៍ទទួលអ្នកស្វែងយល់ ចំនួន៣២នាក់ ឲ្យទទួលជំហានទី១ នេះ។**



Photo: An Rittyrath

កាលពីថ្ងៃអាទិត្យទី១៥ ខែកក្កដា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី នៅព្រះសហគមន៍ កាតូលិកបាត់ដំបង បានប្រារព្ធពិធីទទួលជំហានទី១ របស់សិស្សអប់រំជំនឿថ្នាក់ស្វែងយល់។ សិស្សអប់រំជំនឿ ដែលទទួលជំហានទី១នេះ មានចំនួន៣២នាក់ ក្នុងនោះមានសិស្ស ដែលរៀនជាមួយគ្រូផ្សេងៗគ្នា។ កម្មវិធីនេះមានគោលបំណងចង់អោយគ្រីស្តបរិស័ទ នឹងជាពិសេសគឺសិស្ស ដែលទទួលជំហានទី១ ដឹងថា ព្រះគ្រីស្តជាទីពឹង ព្រះសហគមន៍ជាទីពឹង និងព្រះបន្ទូលជាទីពឹង មានសារៈសំខាន់សម្រាប់ពួកគេ។ ក្នុងវិធីនេះមានលោកបូជាចារ្យ តូតេត ជាបូជាចារ្យគ្រប់គ្រង ព្រះសហគមន៍ កាតូលិកបាត់ដំបង និងមានលោកបូជាចារ្យ ឯកា ម៉ានុច កុមារ ជាអ្នកថ្វាយអភិបូជា ព្រមទាំងមានបងប្រុស បងស្រី រួមជាមួយបងប្អូនគ្រីស្តបរិស័ទយ៉ាងច្រើនកុះករ បានចូលរួមផងដែរ។ ជារៀងរាល់ឆ្នាំព្រះសហគមន៍ តែងតែទទួលសិស្ស ដែលរៀនអប់រំជំនឿផ្នែកស្វែងយល់ អោយទទួលជំហានទី១នេះ។ លោកបូជាចារ្យ តូតេត ក៏បានបំភ្លឺបង្ហាញនូវអត្ថន័យ នៃពិធីជំហានទី១នេះ ដែរថា "យើងសូមយកព្រះគ្រីស្តជាទីពឹង យើងសូមយកព្រះបន្ទូលជាទីពឹង មានន័យថា ជីវិតខ្ញុំនៅក្នុងព្រះបន្ទូល ហើយខ្ញុំសូមចូលរួមជាមួយព្រះសហគមន៍"។ លោកបានបន្តទៀតថា "កូនៗស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ សូមកូនពឹងលើព្រះជាម្ចាស់ សូមចេះបន្ទាបខ្លួនចំពោះព្រះជាម្ចាស់ និងសូមទទួលស្គាល់ព្រះជាម្ចាស់នៃជីវិតរបស់កូនៗ"។ ក្នុងការបកស្រាយរបស់លោកបូជាចារ្យ តូតេត ធ្វើអោយបងប្អូន ដែលទទួលជំហានទី១យល់ច្បាស់ពីអត្ថន័យ នៃពិធីជំហានទី១នេះ។ ដូចនេះដើម្បីឆ្លើយនឹងជំនឿរបស់ពួកគេទៅព្រះជាម្ចាស់ និងព្រះសហគមន៍ កញ្ញា សៀង មួយគាំ មកពីព្រះសហគមន៍ និគម រៀនអប់រំជំនឿពីអ្នកគ្រូ គង់ រ៉េន បាននិយាយថា "ខ្ញុំចង់ស្គាល់ព្រះយេស៊ូ និងចង់ដើរតាមព្រះអង្គ ព្រោះព្រះអង្គជាទីពឹងរបស់នាងខ្ញុំ និងព្រះបន្ទូលជាអាហារចិញ្ចឹមជីវិតរបស់នាងខ្ញុំផងដែរ"។ ក្នុងនោះក៏មានសិស្សអប់រំម្នាក់ទៀតឈ្មោះ ស្រី ច្រិប អាយុ២២ឆ្នាំ មកពីមណ្ឌលសាលិសៀន បានប្រាប់រតនះយើងដែលថា "ខ្ញុំបានរៀនអប់រំជំនឿរយៈពេល២ឆ្នាំហើយ ក្នុងថ្ងៃនេះខ្ញុំសប្បាយចិត្តណាស់ ដែលបានទទួលជំហានទី១នេះ ហើយខ្ញុំតែងតែអធិដ្ឋានជានិច្ច សូមអោយព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកគង់សន្ថិតលើខ្ញុំ ហើយសូមអោយព្រះអង្គ ដឹកនាំខ្ញុំអោយខ្ញុំមានជំនឿលើព្រះអង្គ កាន់តែខ្លាំងឡើងៗ។ ស្របគ្នានោះដែលអ្នកគ្រូអប់រំជំនឿម្នាក់ឈ្មោះ សៅ ឌី អាយុ៣៩ឆ្នាំ ជាគ្រូអប់រំជំនឿថ្នាក់ស្វែងយល់ដំបូង បានមានប្រសាសន៍ថា "ខ្ញុំបានឃើញថា ជំនឿរបស់សិស្សទាំងអស់នេះ ពិតជាសមល្មមនឹងអាចទទួលជំហាននេះ ពីព្រោះគេតែងតែព្យាយាមមកព្រះវិហារ ជារៀងរាល់ថ្ងៃអាទិត្យ ដូចនេះគេស្គាល់ព្រះយេស៊ូច្រើន។ ខ្ញុំមានសេចក្តីរំពឹងទុកថា សិស្សទាំងអស់នេះ នឹងព្យាយាមទំនាក់ទំនងជាមួយព្រះសហគមន៍បន្តទៀតព្រមទាំងព្យាយាមស្គាល់ព្រះអង្គកាន់តែច្បាស់ទៅៗ"។



# ពិធីបុណ្យរំលឹកខួបសន្ត អ៊ីញ៉ាស្យូ ទទួលមរណៈភាព



Photo: An Rittyrath

ដោយៈ មុយ សាម៉េត

កាលពីល្ងាចថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១២ នៅវេលាម៉ោង ០៥:៣០នាទី មានពិធីបុណ្យរំលឹកដល់សន្ត អ៊ីញ៉ាស្យូ ដែលបានទទួលមរណៈភាព នៅក្នុងព្រះសហគមន៍ កាតូលិកបាត់ដំបង។ ពិធីបុណ្យនេះប្រារព្ធឡើងក្នុងគោលបំណង រំលឹកដល់ការមរណៈភាពរបស់សន្ត អ៊ីញ៉ាស្យូ នឹងការបង្ហាញឲ្យឃើញ ពីជីវប្រវិត្តរបស់លោក និងដំណើរជីវិតរបស់លោក មុនឈានទៅដល់ការមាននូវឋានៈ ដែលក្លាយខ្លួនជាប្រធានធំ នៃសហជីវិនគ្រួសារព្រះយេស៊ូ។ ពិធីបុណ្យនេះក៏មានក្បួនដង្ហែរ ដែលចាប់ផ្តើមចេញពីផ្ទះលោកអភិបាល គឺគេឆ្ពោះទៅព្រះវិហារធំ ដោយមានក្រុមឆៃយ៉ាំ អម និងបងប្អូនគ្រីស្តបរិស័ទជាច្រើនទៀតផង។ ក្នុងនោះក៏មានការចូលរួមពីលោកបូជាចារ្យ ១៥អង្គ បងប្រុស បងស្រីនឹងមានមណ្ឌល និងព្រះសហគមន៍ ចូលរួមដូចជាមណ្ឌល ទេពអ៊ឹម អារ៉ូពេ ព្រះសហគមន៍ តាហែន ច្រាបវាល ក្រុមសហជីវិនគ្រួសារព្រះយេស៊ូ យុវជនអេស្ប៉ាញ និងគណៈកម្មការព្រះសហគមន៍ កាតូលិកបាត់ដំបងផងដែរ។ ស្របពេលនោះដែរក្នុងពិធីអភិបូជាក៏មានការបង្ហាញ ស្លាយ និងការរៀបរាប់អំពីជីវប្រវិត្តរបស់សន្ត អ៊ីញ៉ាស្យូ ផងដែលថា "សន្ត អ៊ីញ៉ាស្យូ កើតនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៤៩១ នៅទីក្រុង ឡូយ៉ូឡា ប្រទេស អេស្ប៉ាញ ហើយគាត់គឺជាកូនចៅនៅក្នុងគ្រួសារអភិជនមួយ។ សន្ត អ៊ីញ៉ាស្យូ បានទទួលមរណៈភាព នៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ១៥៥៦។ លោកក៏ក្លាយជាប្រធានធំ របស់ក្រុមសហជីវិនគ្រួសារព្រះយេស៊ូ នៅក្នុងឆ្នាំ១៥៤០"។ ក្នុងនោះដែរលោកបូជាចារ្យ តូតេត បានមានប្រសាសន៍ទាក់ទងទៅនឹង សន្ត អ៊ីញ៉ាស្យូ ក្នុងពេលធ្វើធម៌ទេសនាថា "សន្ត អ៊ីញ៉ាស្យូ ជាមនុស្សបាបខ្លាំងណាស់ ហើយគាត់បានស្រាយបាបរយៈពេល បីថ្ងៃទើបអស់។ គាត់ពិតជាមនុស្សមបាបធ្ងន់ណាស់ ប៉ុន្តែអ្វីមួយផ្សេងទៀត ដែលគាត់បានស្គាល់គាត់ គឺព្រះជាម្ចាស់បានទទួលស្គាល់គាត់ ហើយព្រះជាម្ចាស់បានស្រឡាញ់គាត់យ៉ាងខ្លាំង ដោយគ្មានការប្រែប្រួលទេ។ នេះជាអ្វី ដែលសន្ត អ៊ីញ៉ាស្យូ បានស្គាល់ ទោះគាត់ជាអ្នកបាបយ៉ាងណាក៏ដោយ"។ លោកឪពុកបានបន្តទៀតថា "អ្វីៗទាំងអស់សម្រាប់សន្ត អ៊ីញ៉ាស្យូ សុខចិត្តធ្វើទាំងអ្វី ដែលធ្វើអោយលោកមានទុក្ខវេទនា ហើយធ្វើអោយលោកបានស្គាល់សេរីរុងរឿងពីព្រះជាម្ចាស់ថា មួយណាជាផ្លូវមារសតាំង នឹងមួយណាជាផ្លូវរបស់ព្រះជាម្ចាស់។ នៅចុងបញ្ចប់នៃពិធីអភិបូជា ក៏មានក្រុមយុវជន អេស្ប៉ាញ បានបង្ហាញនូវចំរៀងនឹងច្រៀង ដែលទាក់ទង និងសន្ត អ៊ីញ៉ាស្យា ផងដែរ។ ទាក់ទិនទៅនឹងពិធីបុណ្យរំលឹកខួបរបស់សន្ត អ៊ីញ៉ាស្យូ មានបងប្អូនគ្រីស្តបរិស័ទជាច្រើនបានយល់ និងបានដឹងពីដំណើរជីវិតរបស់សន្ត អ៊ីញ៉ាស្យូ ជាពិសេសអំពីជំនឿដ៏រឹងមាំរបស់លោក។



Photo: Vong Rithy

**កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២ នៅព្រះសហគមន៍កាតូលិក បាត់ដំបង បានរៀបចំកម្មវិធីមួយ ដើម្បីរំលឹកខួបតែងតាំងជា អភិបាល ភូមិភាគបាត់ដំបង របស់លោកអភិបាល គីគេ ហ្វីកា រេដូ។ កម្មវិធីនេះមានអ្នកចូលរួមយ៉ាងច្រើនកុះករ ពីសំណាក់បង ប្រុស បងស្រី មណ្ឌលផ្សេងៗ រួមទាំងបងប្អូនគ្រីស្តបរិស័ទជា ច្រើនទៀតផង។**



Photo: An RittyRath

លោកអភិបាល Jean Pierre Ricard ជាតំណាងក្រុមជ្រើសរើសសម្តេចប៉ាប់ បានមកដល់ប្រទេស កម្ពុជា នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២។ លោកបានមកដល់ព្រះសហគមន៍ កាតូលិកបាត់ដំបង កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ ដោយមកលេងព្រះសហគមន៍ និងចង់ស្គាល់ព្រះសហគមន៍ នៅក្នុងស្រុកខ្មែរ ព្រោះចង់ជួបបងប្អូនគ្រីស្តបរិស័ទ ក្នុងស្រុកខ្មែរផងដែរ។ នៅក្នុងថ្ងៃទី២៦ ក្នុងខែដដែល លោកបានថ្វាយអភិបូជាជាមួយ បងប្អូនគ្រីស្តបរិស័ទ និងចែកព្រះកាយដល់គ្រីស្តបរិស័ទក្នុងពេលអភិបូជាផងដែរ។ លោកអភិបាល នៅប្រទេសខ្មែរចំនួន ១០ថ្ងៃ ដោយចាប់តាំងពីលោកអញ្ជើញមកដល់។

# កម្មវិធីបិទវគ្គការប្រកួតបាល់ទាត់ជ្រើសរើសជើងឯក Bishop Cup ប្រចាំឆ្នាំ២០១២

ដោយៈ មុយ សាម៉េត

ការប្រកួតបាល់ទាត់អបអរសាទរខួប លោកអភិបាល គីគេ ហ្វីការេដូ តែងតាំងជាអភិបាលភូមិភាគបាត់ដំបង បានបញ្ចប់កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ នៅព្រះសហគមន៍ កាតូលិកបាត់ដំបង។ ការប្រកួតនេះមានក្រុមចូលរួមជាច្រើន ហើយក៏មានការបែងចែកកុមារ និងមហាជន ដូចជាមាន ក្រុមបាល់ទាត់ក្រោមអាយុ ១១ ១៤ និង១៦ឆ្នាំ។ ក្នុងនោះការប្រកួតមានរយៈពេលពីរសប្តាហ៍ ហើយចំនែកឯសប្តាហ៍ទី១ ជាការប្រកួតវគ្គជំរុះក្នុងពូល និងសប្តាហ៍ទី២ ជាការប្រកួតវគ្គផ្តាច់ព្រ័តរបស់ក្រុម ដែលបានប្រកួតជំរុះតាមពូលរួច។ ស្របពេលនោះដែរ នៅក្នុងសប្តាហ៍ចុងក្រោយនៃការប្រកួតវគ្គផ្តាច់ព្រ័ត ក្រុមដែលទទួលជើងឯកនឹងដណ្តើមបាននូវចំណាត់ថ្នាក់លេខ១ មានដូចជា ក្រុមក្រោមអាយុ ១១ឆ្នាំ បានទៅលើក្រុម ពេទ្យយាយជី ចំនែកឯក្រុមក្រោមអាយុ ១៩ឆ្នាំ ក៏បានទៅលើក្រុមម្ចាស់ផ្ទះដដែលគឺក្រុម ពេទ្យ- ហើយក្រុមក្រោមអាយុ ១៦ឆ្នាំ បានទៅលើក្រុម រុយខ្មៅ សម្រាប់ក្រុមមហាជនបានទៅលើក្រុម ធនាគារស្រូវកម្ពុជា។ ការបញ្ចប់ និងបិទវគ្គផ្តល់នូវពានរង្វាន់ ដល់ក្រុមទទួលជ័យលោភី ក៏មានការចូលរួមពីសំណាក់ លោកអភីបាល គីគេ និងគណៈកម្មការណ៍ ដែលបានរៀបចំផងដែរ។ សូមបញ្ជាក់ថា ការប្រកួតបាល់ទាត់ពានរង្វាន់អបអរសាទរ របស់លោកអភិបាល គឺមានរយៈពេលបីឆ្នាំរួចមកហើយ នេះក៏ជាឆ្នាំទីបីផងដែរសម្រាប់ការរៀបចំអោយមានការប្រកួតនេះឡើងក្នុងឆ្នាំ២០១២នេះ។



Photo: An RittyRath

Photo: An Rittiy Rath



**ការប្រកួតបាល់មិត្តភាព ដែលប្រព្រឹត្តទៅនៅទីលានបាល់ទាត់ ព្រះសហគមន៍ កាតូលិកបាត់ដំបង កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១២។ ការប្រកួតនេះមានចំនន្ទបួនក្រុម ចូលរួមដូចជាក្រុមបាល់ទាត់ ពេទ្យយាយជី ភូមិបារាំង បរិស្ថាន មណ្ឌល ទេពអ៊ុម និងក្រុមយុវជន អេស្ប៉ាញ។ ការប្រកួតនេះគោលបំណង ចង់ស្គាលគ្នាទៅវិញទៅមក រវាងយុវជនព្រះសហគមន៍ កាតូលិកបាត់ដំបង និងយុវជន មកពីប្រទេស អេស្ប៉ាញ ក្នុងរដូវឈប់សម្រាក់ ពីការសិក្សារបស់ពួកគេជារៀងរាល់ឆ្នាំ។**

# កម្មវិធីបិទវគ្គសិស្សអប់រំជំនឿ



Photo: An RittyRath

កម្មវិធីអប់រំជំនឿរបស់ព្រះសហគមន៍ កាតូលិកបាត់ដំបង បានប្រារព្ធពិធីបិទវគ្គកាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១២ វេលាម៉ោង ០១:០០ថ្ងៃត្រង់នៅលើអាគារវប្បធម៌។ ក្នុងកម្មវិធីបិទវគ្គនោះមានការចូលរួមពីលោកបូជាចារ្យគ្រប់គ្រងព្រះសហគមន៍ កាតូលិកបាត់ដំបង បងស្រី លក្ខិណា និងជាបងស្រីគ្រប់គ្រងកម្មវិធីអប់រំជំនឿ ព្រមទាំងមានលោកគ្រូ អ្នកគ្រូអប់រំជំនឿរួមជាមួយសិស្សដែលរៀនអប់រំជំនឿយ៉ាងច្រើនកុះករផងដែរ។ នេះជាលើកទី២ហើយ ដែលបានប្រារព្ធកម្មវិធីបិទវគ្គសិស្សទទួលការអប់រំជំនឿនេះ។ គោលបំណងកម្មវិធីទាំងមូលនេះ ចង់ឲ្យសិស្សទទួលការអប់រំជំនឿស្គាល់ពីតម្លៃនៃការសិក្សាអំពីជំនឿ និងមើលឃើញសិស្សដែរពូកែ ដើម្បីយកជាគំរូតាម។ ក្នុងកម្មវិធីទាំងមូលនេះមានការលេងល្បែងកំសាន្តជាច្រើន ដែលធ្វើអោយសិស្សទាំងអស់សប្បាយរីករាយ ហើយម្យ៉ាងវិញទៀតមានការចែកនូវរង្វាន់ដល់សិស្សពូកែ ហើយនិងមានការចែកនូវរបស់លេង និងប្រើប្រាស់ដល់សិស្ស ដែលបានមករៀនទៀងទាត់ផងដែរ។ ខណៈពេលនោះក៏មានការឆ្លើយនឹងសំនួរ ដែលទាក់ទងទៅនឹងការរៀបនស្វែងយល់ពីព្រះជាម្ចាស់អស់រយៈពេលមួយឆ្នាំ ហើយអ្នក ដែលឆ្លើយនូវសំនួរបានត្រឹមត្រូវ មានការទទួលរង្វាន់ពីបងស្រី លក្ខិណា ដូចជា បន្ទោងខ្សែរករូបព្រះ និងវត្ថុអនុស្សាវរីយ៍ជាច្រើន។ កម្មវិធីនេះបានបញ្ចប់ទៅដោយល្អប្រសើរ ដោយមានការសប្បាយរីករាយពីសិស្ស ដែលបានទទួលរង្វាន់ ដែលខ្លួនបានយ៉ាងច្រើនជាពិសេស មិនត្រឹមតែទទួលបានរង្វាន់នោះទេ ប៉ុន្តែពួកគេទទួលបានជំនឿដ៏ល្អពីលោកគ្រូ អ្នកគ្រូ អស់រយៈពេលមួយឆ្នាំពេញនេះ។

**ដោយៈ អាន ឫទ្ធីរដ្ឋ**